មាត្រា ៦ : អនុក្រឹត្យនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ ព្រះហស្តលេខា និង ត្រា នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២ ហត្ថលេខា និង ត្រា ហ៊ុន សែន

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៦០ អនក្រ

## ស្តីពីបង្កើតអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរការងារចាំបាច់

## សំរេច

មាត្រា ១ : បង្កើតអាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅក្រោមនិវាទផ្ទាល់របស់សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានសមត្ថកិច្ចចាត់ចែង និង គ្រប់គ្រងការធ្វើនិតិសម្បទា និងការអភិវឌ្ឍន៍អាកាសយានដ្ឋានក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

មាត្រា ២ : អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចខាងក្រោម ៖

-ទទួលខុសត្រូវក្នុងការធ្វើនិតិសម្បទា និងការអភិវឌ្ឍន៍អាកាសយានដ្ឋានទាំងអស់នៅទូទាំងប្រទេសដោយធ្វើការសិក្សាស្រាវជ្រាវកសាងប្លង់មេ (Master Plan)និង កសាងទិសដៅនៃការអភិវឌ្ឍន៍ អាកាសយានដ្ឋានសំរាប់រយៈពេល ២០ ឆ្នាំ ។

-ពិនិត្យ និង ផ្តល់ការណែនាំ លើរាល់សេចក្តីស្នើសុំធ្វើការអភិវឌ្ឍន៍អាកាសយានដ្ឋាន របស់អ្នកវិនិយោគបរទេស ឬ ក្នុងស្រុក ។

-ត្រួតពិនិត្យ និង ទទួលខុសត្រូវលើរាល់ការងារសាងសង់អាកាសយានដ្ឋាន។

-ផ្លាស់ប្តូរបទពិសោធន៍ និង បច្ចេកវិទ្យាទំនើបរវាងអ្នកជំនាញការបរទេសដែលចូលមក ជួយធ្វើការនៅកម្ពុជាជាមួយនិងអ្នកឯកទេសខ្មែរ ។

មាត្រា ៣ : អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ ជាប្រធាន និង មានឯកឧត្តម ម៉ិច សូផាណា ជាអនុប្រធាន ដើម្បីជួយការងារ ។

-រចនាសម្ព័ន្ធរបស់អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ ដូចមានក្នុងឧបសម្ព័ន្ធ ជូនភ្ជាប់ ។

-ក្របខណ្ឌមន្ត្រីរាជការសំរាប់បំរើ អោយអាជ្ញាធរនេះត្រូវកំណត់ដោយរាជរដ្ឋាភិបាល កម្ពុជា ។

មាត្រា ៤ :ក្រៅពីភារកិច្ចខាងលើ អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជាពុំមានសិទ្ធិដឹកនាំ និង ចាត់ចែងក្នុងកិច្ចការរដ្ឋបាល និង អាជីវកម្ម របស់អាកាសយានដ្ឋាន និង របស់ផ្នែកអាកាសចរឡើយ ។

មាត្រា ៥ : អាជ្ញាធរអភិវឌ្ឍន៍អាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជាមានការិយាល័យធ្វើការរបស់ខ្លួនមួយដោយឡែក និង មានសិទ្ធិប្រើប្រាស់ត្រារបស់ខ្លួនដោយឡែក ។

-ការចំណាយទាំងអស់បំរើអោយសកម្មភាពរបស់អាជ្ញាធរនេះជាបន្ទុករបស់ថវិកាជាតិ ។

មាត្រា ៦ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន អាជ្ញាធរអាកាសចរស៊ីវិល និងរដ្ឋមន្ត្រីរដ្ឋលេខាធិការនៃក្រសួង និង ស្ថាប័នពាក់ព័ន្ធត្រូវទទួល អនុវត្តអនុក្រឹត្យនេះចាប់តាំង ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះ ហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

# អង្គការលេខនៃអាជ្ញាធរអភិវឌ្ឍន៍
# អាកាសយានដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា

* * * * *

